**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

No. 25 PR-17/EoJ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧

# កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2017
# (សន្និសីទនិស្សិតបណ្តាប្រទេសអាស៊ាន-ជប៉ុន)

តាមរយៈការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន១២រូបនឹងធ្វើដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី១៨ ដល់ថ្ងៃទី២៦ ខែកញ្ញា ជាមួយក្រុមយុវជនមកពីបណ្តាប្រទេសអាស៊ាន ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិត និងយុវជនរវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើតដែលហៅកាត់ថាJENESYS 2017។

ក្រោយការទស្សនានៅទីក្រុងតូក្យូ ក្រុមយុវជននឹងត្រូវបែងចែកទៅតាមក្រុមអាស្រ័យលើប្រធានបទនីមួយៗ ហើយក្រុមយុវជននឹងទៅទស្សនកិច្ចនៅខេត្តអ៊ីវ៉ាតិ ខេត្តមីយ៉ាគី ខេត្តហ្វូគូអ៊ីកា រឺខេត្តគូម៉ាម៉ូតុ ដើម្បីចូលរួមសន្និសីទនិស្សិតបណ្តាលប្រទេសអាស៊ាន-ជប៉ុន និងកម្មវិធីផ្លាស់ប្តូរផ្សេងទៀតជាមួយស្ថាប័ននិងក្រុមហ៊ុនមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រធានបទរបស់ខ្លួន។ ក្រុមយុវជនក៏នឹងមានឱកាសទៅទស្សនានៅតំបន់ប្រវត្តិសាស្ត្រមួយចំនួននៅប្រទេសជប៉ុន។ មានជូនភ្ជាប់តារាងកម្មវិធីលម្អិត។

កម្មវិធី JENESYS 2017 មានគោលបំណងជម្រុញការយល់ដឹង និងការកសាងទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់ ហើយតាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែស៊ីជម្រៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធន៍របស់ខ្លួនឲ្យបានទូលំទូលាយទៅកាន់ប្រជាជនកម្ពុជា បន្ទាប់ពីវិលត្រលប់មកវិញ។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161, Fax: 023 216 162*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*